**សង្ខេបព័ត៌មាន**

11/2017

## ក្រុមកម្មកររោងចក្រកាត់ដេរ ហ្គារ៉ិន្ត បិទផ្លូវលេខ២១ តវ៉ាទាមទារបើកប្រាក់ខែ

កណ្ដាល៖ សេចក្ដីរាយការណ៍បានឲ្យដឹងនៅព្រឹកថ្ងៃទី ២០ វិច្ឆិកា ២០១៧នេះថា ក្រុមកម្មកររាប់រយនាក់នៅក្នុងរោងចក្រកាត់ដេរហ្គារ៉ិន្ត បាននាំគ្នាបិទផ្លូវលេខ២១ ក្នុងបំណងតវ៉ាឲ្យថៅកែបើកប្រាក់ខែ។

បើតាមមន្ត្រីនរគបាលបានឲ្យដឹងថា ការតវ៉ាទាមទារនេះ មានទីតាំងកើតលើផ្លូវលេខ២១០ ស្ថិតនៅក្នុងភូមិសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

ក្រោយពីមានការសម្របសម្រួលពីអាជ្ញាធរ ខាងភាគីរោងចក្របានយល់ព្រមបើកប្រាក់ខែជូនកម្មករក្នុង១នាក់ ១៥០ ដុល្លារ នៅម៉ោង ២រសៀលថ្ងៃដដែលនេះ ប៉ុន្តែភាគីកម្មករមិនយល់ព្រមនោះទេ។

អាជ្ញាធរមានសមត្ថកិច្ច កំពុងជួយអន្តរាគមន៍លើបញ្ហាសន្តិសុខ និងសណ្ដាប់ធ្នាប់ជូនកម្មករ កម្មការិនី។

សូមបញ្ជាក់ថា កម្មករក្នុងរោងចក្រកាត់ដេរ ហ្គារ៉ិន្តនេះមានគ្នាចំនួន ៩៣៥នាក់ ហើយបានធ្វើការតវ៉ាបិទផ្លូវ មានចំនួន ២០០នាក់។

**សន្ទូច** 20/11/2017

## ក្រុមវិនិយោគចិន ស្វែងរកឱកាស

**ភ្នំពេញ៖** ក្រុមពាណិជ្ជករមកពីខេត្ត Fujian ភាគខាងកើតប្រទេសចិនកាលពីម្សិលមិញបានអះអាងថា ខ្លួនកំពុងស្វែងរកពង្រីកពាណិជ្ជកម្មនៅប្រទេសកម្ពុជាលើអាជីវកម្ម លក់ផលិតផលទាក់ទងនឹងអគ្គិសនី និងផលិតផលសម្លៀកបំពាក់។

ថ្លែងនៅក្នុងសិក្ខាសិលា ស្ដីពីពាណិជ្ជកម្ម និងបណ្ដាញទេសចរណ៍ កម្ពុជា

Fujian កាលពីម្សិលមិញ លោក Huang Deshi នាយករងក្រុមប្រឹក្សានាយកដ្ឋានពាណិជ្ជកម្មខេត្ត Fujian បានឲដឹងថា រហូតមកដល់ពេលនេះ មានគំរោងវិនិយោគសរុប ១៨ ដែលពាណិជ្ជករខេត្ត Fujian បានវិនិយោគនៅប្រទេសកម្ពុជា ដោយមានទឹកប្រាក់សរុប ៣៨០លានដុល្លារ។

លោកបន្ថែមថា មានកាសអាជីវកម្មជាច្រើននៅកម្ពុជា ហើយសក្តានុពលនេះកំពុងទាក់ទាញពាណិជ្ជកម្មរបស់ប្រទេសចិនមកពីខេត្ត Fujian ក្នុងការវិនិយោគប្រាក់របស់ពួកគេ។

លោកបន្ថែមថា ដោយមានទំនាក់ទំនងល្អរវាងកម្ពុជា និងចិន ទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា និងខេត្ត Fujian នឹងមានការផ្លាស់ប្តូរនៅក្នុងនិន្នាការវិជ្ជមាន។

យោងតាមលោក Huang ពាណិជ្ជកម្មទ្វេរភាគីរបស់កម្ពុជា និងខេត្ត Fujian នាំចេញមកកម្ពុជាមានចំនួន ២៥០លានដុល្លារ កាលពីឆ្នាំ ២០១៦ ដែលខេត្ត Fujian នាំចេញមកកម្ពុជា ចំនួន ១៧៤លានដុល្លារ ខណៈនៅសល់គឺគឺការនាំចេញពីប្រទេសកម្ពុជា។ ក្នុងអំឡុង ៩ ខែដំបូងនេះ ពាណិជ្ជកម្មទ្វេរភាគីជាមួយខេត្ត Fujian មានទឹកប្រាក់ចំនួន ១៨០ លានដុល្លារ។

វេទិកាកាលពីម្សិលមិញមានក្រុមហ៊ុនមកពីប្រទេសចិនប្រហែល ៥០ ចូលរួម ដោយមានការចូលរួមពីមន្ត្រីកម្ពុជាមកពីក្រសួងពាណិជ្ជកម្មក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC ) និងក្រុមហ៊ុនជាច្រើនមកពីសមាគមពាណិជ្ជកម្មកម្ពុជា ចិននៅក្នុងប្រទេសកម្ពុជា។

**ភ្នំពេញប៉ុស្ត** 22/11/2017

## ពលកររួមគ្នា ដើម្បីសិទ្ធិគ្រប់គ្រាន់នៅក្នុងការងារ

**រាជធានីភ្នំពេញ៖** នៅព្រះវិហារសន្តប៉ូល និងសន្តសិលា នៃមណ្ឌលសកម្មភាពភ្នំពេញថ្មី នាថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៧នេះ គណៈកម្មការពលករនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំកម្មវិធីមហាស្រពពលករមួយ ដែលទាក់ទងទៅនឹងប្រធានបទ ពលកររួមគ្នាដើម្បីសិទ្ធិគ្រប់គ្រាន់ក្នុងការងារ។

កម្មវិធីនេះ មានការចូលរួមជាកិត្តិយសពីសំណាក់លោកអភិបាល អូលីយេ និងលោកបូជាចារ្យមួយចំនួន ដែលជួយនៅក្នុងគណកម្មការពលករ រួមនឹងបងប្អូនកម្មករ កម្មការិនីប្រមាណជាង ១០០នាក់។ កម្មវិធីនេះមានគោលបំណងជួបជុំជាមួយបងប្អូនកម្មករកម្មការិនីនៅតាមបណ្តារោងចក្រមួយចំនួនក្នុងរាជធានីភ្នំពេញ ដើម្បីអោយពួកគេមានឱកាសកំសាន្តរួមគ្នា ចែករំលែកបទពិសោធន៍នៃជីវិតរស់នៅរបស់ពួកគេម្នាក់ៗដែលធ្លាប់បានជួបប្រទះក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

លោកអូលីវីយេ ជ្មីតហាស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍លើកទឹកចិត្តកម្មករ កម្មការិនីដែលចូលរួមកម្មវិធីនាឱកាសនោះថា នេះជាឱកាសមួយសំរាប់ព្រះសហគមន៍កាតូលិកដើម្បីបង្ហាញពីការយកចិត្តទុកដាក់សម្រាប់កម្មករ ដែលសព្វថ្ងៃនៅប្រទេសកម្ពុជាមានកម្មករប្រមាណជាង៨០ម៉ឺននាក់។ បើទោះបីព្រះសហគមន៍កាតូលិកមិនមានសកម្មភាពច្រើនក្តី ប៉ុន្តែព្រះសហគមន៍បានរៀបចំឲមានមណ្ឌលមួយ សម្រាប់ទទួល និងជួយដល់កម្មករ កម្មការិនីខ្លះៗ ដែលធ្វើការតាមរោងចក្រ។ យើងមានក្រុមចលនាកម្មករគ្រីស្តបរិស័ទដើម្បីប្រមូលកម្មករ កម្មការិនី ដើម្បីរិះគិតអំពីអត្ថន័យនៃការងារ និងរិះគិតអំពីជីវិតនៃការរស់នៅជាក្រុមជាដើម។

លោកដឺហ្វុង យ៉ាន ជាអ្នកទទួលខុសត្រូវគណៈកម្មការពលករនៃព្រះសហគមន៍កាតូលិកភ្នំពេញ បានឲដឹងថា មហាស្រពពលករ គឺជារួមគ្នារៀបចំឡើងដោយក្រុមកម្មករ ដែលភាគច្រើនពួកគេធ្វើការនៅតាមរោងចក្រ។ ចំពោះប្រធានបទឆ្នាំនេះ គឺពួកគេបានជ្រើសរើសប្រធានបទ “ ពលកររួមគ្នា ដើម្បីសិទ្ធិគ្រប់គ្រាន់នៅក្នុងការងារ ”។ ដែលប្រធានបទ គឺចង់ផ្ញើរសារទៅដល់ថ្នាក់ដឹកនាំរោងចក្រ គិតឲបានវែងឆ្ងាយជាងហ្នឹងសំរាប់អ្នកដទៃ តែសូមឲថ្នាក់ដឹកនាំនៅតាមរោងចក្រនានា ត្រូវគោរពសិទ្ធិរបស់ពួកគាត់ដែលជាកម្មករ។ ដូចនេះហើយកម្មករទាំងអស់ ពួកគាត់ទាមទារ និងចង់បានសិទ្ធិគ្រប់គ្រាន់នៅក្នុងការងារទាំងនោះ។

លោក ឆោម សុធា អាយុ ៣៣ឆ្នាំ ជាកម្មករនៅក្រុមហ៊ុន ISI ក្នុងរាជធានីភ្នំពេញ ដែលបានចូលរួមកម្មវិធីនោះបានចាប់អារម្មណ៍ថា កម្មវិធីជំនួបកម្មករ កម្មការិនីនាឱកាសនេះ គឺមានគោលបំណងជួយលើកទឹកចិត្តបងប្អូនកម្មករទាំងអស់ឲមានការតស៊ូ និងចេះរួបរួមគ្នា ដោយស្វែងយល់អំពីច្បាប់ការងារផ្សេងៗ និងចេះតស៊ូមតិ ដោយចេះទាមទារសិទ្ធិការងាររបស់ខ្លួនដូចដែលមានចែងក្នុងច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជាយើង។

គួរបញ្ជាក់ថា គណកម្មការពលករ គឺជាគណកម្មការមួយ ដែលបានបង្កើតឡើងដោយព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញក្នុងគោលបំណងជួយដល់បងប្អូនកម្មករ កម្មការិនីនៅតាមរោងចក្រមួយចំនួន ទាក់ទងទៅនឹងសិទ្ធិការងារ ការរួបរួមគ្នា និងការតស៊ូមតិ ដើម្បីឲមានការគោរពសិទ្ធិ និងគោរពច្បាប់ការងារជាដើម។

ដោយ CSC

RFA 30/11/17